# អ្នកនាំសារ

The messenger




## សិទ្ធិកុមារ និង ពន្ធនាគារ

តាមការប៉ាន់ប្រមាណមានក្មេងៗចំនួន ១០០ ០០០* នាក់ ត្រូវបានគេឃុំឃាំងនៅក្នុងពិភពលោក ។ ក្នុងឱកាសនៃយុទ្ធនាការ អូរីហ្សង់ ( HORIZON ) ដែលមានន័យថា "ការប្រមើលមើលទៅកាន់អនាគត" របស់ "អង្គការជួយសង្គ្រោះកុមារនៅកម្ពុជា (BICE ) " ព្រឹត្តិបត្រ *អ្នកនាំសារ* របស់ព្រះសហគមន៍កាតូលិក បានបង្ហើបទ្វារពិភពបិទជិតនេះ ។

តើមានក្មេងៗស្ថិតក្នុងពន្ធនាគារនៅប្រទេសកម្ពុជាដែរឬទេ? តើសិទ្ធិរបស់ពួកគេត្រូវបានគោរពដែរឬទេ? មានចំលើយឆ្លើយតបទៅនឹងសំនួរទាំងនេះនៅក្នុងការអង្កេតរបស់យើង ។ (*យើងគ្មានស្ថិតិច្បាស់លាស់ទេ )


ពត៌មានពីព្រះសហគមន៍កាតូលិក – Internal Use ឆ្នាំទី ០២ លេខ ១៤ ខែ មិថុនា ឆ្នាំ ២០០៤

# សិទ្ធិកុមារ នៅកម្ពុជា ...




PHOTO COVER lizzie Sadin

## ការប្រមើលមើលទៅកាន់អនាគត

យុទ្ធនាការរបស់ "អង្គការជួយសង្គ្រោះកុមារនៅកម្ពុជា" **(BICE)** គឺជួយកុមារដែលត្រូវគេដកហូតយកនូវសេរីភាព។ ទោះបីមាន ១៩១ ប្រទេសលើពិភពលោក ដែលបានអនុម័តអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារក៏ដោយ នៅឆ្នាំ ២004 នេះ មានប្រទេសជាច្រើនបានរំលោភលើសិទ្ធិកុមារក្នុងពន្ធនាគារ។ យុទ្ធនាការ "ប្រមើលមើលទៅកាន់អនាគតកុមារ" មានគោលបំណងលើក តម្លៃសំរាប់កុមារ ដែលបានប្រព្រឹត្តបទល្មើស។ គេមិនមែនជាជនល្មើស ដែលត្រូវទទួលទោសជាសាធារណៈឡើយ។ ប៉ុន្តែ គេជាអ្នកដែលងាយធ្វើអោយខូចខាតឬឈឺចាប់ និងត្រូវទទួលផលប្រយោជន៍ពីវិធានការនៃការអប់រំដ៏ត្រឹមត្រូវមួយ។

### អង្គការជួយសង្គ្រោះកុមារនៅកម្ពុជា

ជាអង្គការក្រៅរដ្ឋាភិបាលមួយដែលបង្កើតឡើងនៅឆ្នាំ ១៩៤៨ ដើម្បីការពារសិទ្ធិរបស់កុមារ។ អង្គការចូលធ្វើអន្តរាគមន៍ ដើម្បីលើកកំពស់សេចក្តីថ្លៃថ្នូររបស់កុមារ និងសិទ្ធិរបស់ពួកគេប្រឈមមុខទៅនឹងវិបត្តិគ្រប់ទំរង់។ អង្គការមានវត្តមានក្នុងប្រទេសចំនួន ៧៥ ជាមួយនឹងបណ្តាញ ដែលមាន ២៣០ តំបន់ជាដៃគូ។

កម្ពុជាគឺជាប្រទេសមួយ ដែលទទួលការរងរបួស។ ប្រជាជនត្រូវបានស្លាប់យ៉ាងរង្គាលដោយសារសង្គ្រាម។ របបខ្មែរក្រហមបានអនុវត្តនូវការសម្លាប់រង្គាល ហើយសង្គ្រាមទ័ពព្រៃបានបន្តរហូតដល់ឆ្នាំ ១៩៩៩។ សព្វថ្ងៃប្រទេសកម្ពុជា ប្រឈមមុខចំពោះស្ថានភាពសេដ្ឋកិច្ច ដែលគួរឱ្យខ្វល់អំពល់ និងត្រូវពុះពារចំពោះភាពអសកម្មនានា ដូចជាអំពើពុករលួយ និងគ្រោះអនក្ខរកម្មជាដើម។ ទោះបីមានសញ្ញាខ្លះស្តីពីការគោរពតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យយ៉ាងណាក្តី ក៏ការព្រួយបារម្ភរបស់សហគមន៍អន្តរជាតិ គឺស្ថិតនៅលើអ្វីៗដែលទាក់ទងទៅនឹងកំនែទំរង់ក្នុងប្រព័ន្ធតុលាការ លើអំពើហិង្សានយោបាយ លើការជួញដូរស្ត្រីនិងកុមារជាដើម។ ស្ថានការណ៍មិនគោរពសិទ្ធិមនុស្ស និងការរួចទោស នៅតែមានជាអចិន្ត្រៃយ៍។ នៅក្នុងលក្ខខ័ណ្ឌមិនអនុគ្រោះទាំងនេះ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ដែលបានចុះហត្ថលេខាដោយប្រទេសកម្ពុជានៅថ្ងៃទី ២២ កញ្ញា ១៩៩២ មិនត្រូវគេអនុវត្តបានពេញលេញឡើយ។

### គ្មានយុត្តិធម៌សំរាប់អនីតិជន

នៅប្រទេសកម្ពុជា ការអនុវត្តច្បាប់មិនមានតុលាការសំរាប់អនីតិជនឡើយ។ ច្បាប់ដែលអនុវត្តទៅលើអនីតិជន គឺជាច្បាប់សំរាប់មនុស្សពេញវ័យ។ ពន្ធនាគារដោយឡែកសំរាប់អនីតិជនក៏គ្មានដែរ។ ដូចនេះ អនីតិជន និងមនុស្សពេញវ័យ ត្រូវគេឃើញទទួលយកលក្ខខ័ណ្ឌដូចគ្នា ក្នុងការឃុំខ្លួន ការវិនិច្ឆ័យ និងការដាក់ទោស។

ប៉ុន្តែ នៅក្នុងអត្ថបទមាត្រា ១៤ នៃក្រមព្រហ្មទណ្ឌចែងថា "អនីតិជនអាយុក្រោម ១៣ ឆ្នាំ មិនអាចត្រូវឃុំឃាំងបានឡើយ ទោះជាក្នុងករណីបណ្តោះអាសន្នក្តី។ អនីតិជនដែលមានអាយុពី ១៣ ទៅ ១៨ ឆ្នាំ គេមិនអាចឃុំឃាំងក្នុងរយៈពេលហួសពីមួយខែឡើយ លើកលែងតែករណីប្រព្រឹត្តបទឧក្រិដ្ឋ ដែលការដាក់ទោសត្រូវបានធ្វើទ្វេ"។ នៅក្នុងករណីទាំងនេះ ចំនួនដ៏ច្រើននៃអនីតិជនត្រូវបានគេឃុំឃាំងក្នុងរយៈពេលកាន់តែយូរ (យ៉ាងតិចបំផុត ២ ខែ) តាមរបៀបបង្ការជាមុន ហើយអាចត្រូវបានផ្តន្ទាទោស ជាទំងន់ដោយដាក់ពន្ធនាគារ នេះស្ថិតនៅក្នុងលក្ខខ័ណ្ឌមិនអាចទទួលយកបានទេ។

### មន្ទីរឃុំឃាំង និងមជ្ឈមណ្ឌលនានា

មជ្ឈមណ្ឌលស្តារនីតិសម្បទា Youth Rehabilitation Center (YRC) នៅភ្នំពេញ គឺជាមជ្ឈមណ្ឌលអប់រំតែមួយគត់ ដែលផ្តល់ការអប់រំដល់អនីតិជន និងគាំទ្រដោយរដ្ឋាភិបាល។ នៅក្នុងមណ្ឌលមិនអនុញ្ញាតអោយចេញចូលជាសាធារណៈទេ។ មជ្ឈមណ្ឌលនេះបានទទួលក្មេងប្រុសៗមានអាយុពី ៧ ដល់ ១៨ ឆ្នាំ ចំនួន ១២២ នាក់ ដែលស្នាក់នៅពី ៣ ទៅ ៦ ខែ។ ដោយមានភាពខ្វះខាត ការរស់នៅមានការលំបាកក្រៃលែង ដូចជាបញ្ហាអនាម័យ ការរស់នៅច្របូកច្របល់លាយឡំគ្នានិងជំងឺស៊ីដា។

នៅពេលក្មេងម្នាក់ត្រូវបានចាប់ខ្លួនដោយកំហុសតូចតាច ក្រោមលេសផ្សេងៗ គ្រួសាររបស់ក្មេងនោះ គ្មានដំណោះស្រាយអ្វីផ្សេងក្រៅពីផ្តល់ប្រាក់ដល់ប៉ូលីស ដើម្បីឱ្យក្មេងបានរួចខ្លួន។ ចំពោះទោសធ្ងន់ធ្ងរជាងនេះ ប៉ូលីសយកលេសជំរះរឿងក្តីអោយជ្រះស្រលះស្រុះស្រួលគ្នា ដោយកំហែងយកលុយពីគ្រួសារអ្នកដែលប្រព្រឹត្តបទល្មើស ជាអំពើខុសច្បាប់ទាំងស្រុង។

នៅក្នុងសង្គមអំពើពុករលួយ និងអស្ថេរភាពមានជាអចិន្ត្រៃយ៍ ជាញឹកញាប់ក្នុងករណីមានទោសធ្ងន់ លោកចៅក្រមតាមរយៈជំនួយការរបស់គាត់ ចរចាជាមួយគ្រួសារអ្នកដែលប្រព្រឹត្តបទល្មើសអំពីតំលៃដែលត្រូវបង់ ដើម្បីសំរាលទោស។ នៅក្នុងករណីទាំងនេះ បើគ្មានការធ្វើអន្តរាគមន៍ ពីអង្គការក្រៅរដ្ឋាភិបាល ឬមេធាវី ការធានាឱ្យមានយុត្តិធម៌ ប្រកបដោយសមធម៌ គឺមិនអាចកើតបានឡើយ។

**BICE**



រង់ចាំការអប់រំពីរដ្ឋាភិបាល

### អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ...

មនុស្សស្ទើរតែទាំងអស់ បានយល់ និងទទួលស្គាល់ថា មនុស្សដែលអាយុក្រោម ១៨ ឆ្នាំ គឺជាកុមារ ហើយត្រូវការជាចាំបាច់នូវការការពាជាពិសេស។

អនុសញ្ញាដែលទាក់ទងនិងសិទ្ធិកុមារ គឺសន្ធិសញ្ញាសិទ្ធិមនុស្ស។ អនុសញ្ញានោះបានរៀបរាប់នូវសិទ្ធិ និងការចែងលក្ខខ័ណ្ឌនូវវិធីសាស្ត្រដែលប្រទេសទាំងអស់ ដែលត្រូវតែអនុវត្តតាមមាត្រា ៥៤ និងឯកសារពីរបន្ថែមទៀត។

**ផលប្រយោជន៍ដ៏ល្អបំផុត របស់កុមារ មាត្រា ៣ នៃអនុសញ្ញា:** ក្នុងសកម្មភាពទាំងអស់ទាក់ទិននិងកុមារ ដូចជា ស្ថាប័នសង្គមកិច្ចសាធារណៈ ឯកជន តុលាការ អាជ្ញាធររដ្ឋបាល ផលប្រយោជន៍កុមារត្រូវចាត់ទុកជាកត្តាចម្បង។ រដ្ឋត្រូវធានាដល់កុមារគ្រប់រូបនូវកិច្ចគាំពារថែរក្សាផ្នែកសុខមាលភាព។

**សិទ្ធិក្នុងការមានជីវិត និងការរីកចំរើនលូតលាស់ មាត្រា ៦ នៃអនុញ្ញា:** មាត្រានេះតម្រូវឱ្យរដ្ឋជាភាគីទទួលខុសត្រូវផងដែរថា កុមារគ្រប់រូបត្រូវតែមានសិទ្ធិ ដើម្បីមានជីវិតមិនអាចដកហូតបាន។ រដ្ឋត្រូវធានាការរស់នៅ ព្រមទាំងការចំរើនលូតលាស់របស់កុមារឱ្យបានកំរិតខ្ពស់បំផុត។

**ច្បាប់ព្រហ្មទណ្ឌអន្តរកាលៈ** មាត្រា ១៤ កថាខ័ណ្ឌ ៥ អនីតិជនអាយុតិចជាង ១៣ ឆ្នាំ មិនត្រូវជាប់ឃុំជាបណ្តោះអាសន្នទេ។ អនីតិជនតិចជាង ១៣ ដល់ ១៨ ឆ្នាំ មិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្ន លើសពី ១ ខែទេ។ រយៈពេលនេះអាចធ្វើឡើងជាពីរ បើសិនជាមានការចោទប្រកាន់ ពីបទល្មើសឧក្រិដ្ឋណាមួយ។

### អង្គការជួយសង្គ្រោះកុមារ



លោក ប៉ាវ វណ្ណៈ ជាអ្នកសម្របសម្រួលកម្មវិធីមានប្រសាសន៍ថា "អង្គការមានកម្មវិធីជួយដល់កុមាររងគ្រោះដោយការជួញដូរការរំលោភ។ មានការបង្កើតបណ្តាញតាមភូមិចំនួន ២៣ ក្នុងមួយភូមិមានបណ្តាញពីរនាក់ ម្នាក់ជាមេភូមិ និងម្នាក់ទៀតជាពលរដ្ឋធម្មតា។ ក្រៅពីនេះទៀតមានការបង្កើតឱ្យមានក្រុមអ្នកស្ម័គ្រចិត្តជាមនុស្សចាស់ (ទាក់ទងឪពុកម្តាយដែលជួបបញ្ហាជីវភាព) អ្នកស្ម័គ្រចិត្តជាកុមារ (កុមារងាយទាក់ទងនិងកុមារដូចគ្នា ពេលខ្លះកុមារមិនហ៊ានប្រាប់រឿងដល់មនុស្សចាស់ទេ)។ បណ្តាញទាំងនោះនឹងផ្តល់ពតិមានពាក់ពន្ធ័ទៅអាជ្ញាធរ"។ អង្គការមានកម្មវិធីដូចខាងក្រោម:

បញ្ជូនក្មេងនោះទៅសាលារដ្ឋដោយជួយឧបត្ថម្ភជាសម្ភារៈផ្សេងៗសម្រាប់សិក្សា។

ជួយសង្គ្រោះធ្វើតាមរយៈបណ្តាញដោយផ្តល់ពតិទៅអាជ្ញាធរ និងធ្វើការទំនាក់ទំនងជាមួយអង្គការផ្សេងៗ ផ្សព្វផ្សាយអប់រំដល់បណ្តាញ យកទៅអប់រំបន្តដល់សហគមន៍។ អង្គការកំពុងធ្វើការដោយផ្ទាល់ជាមួយកុមារចំនួន ២៣០ នាក់ និងដោយប្រយោលចំនួន ២000 នាក់។ ឪពុកម្តាយលក់កូនរបស់គេដោយសារបញ្ហាជីវភាព ហើយក្មេងមួយចំនួនប្រើប្រាស់គ្រឿងញៀន និងមានអំពើហិង្សាក្នុងគ្រួសារ។

ក. គឹម សំអាត

# កុមារត្រូវបានដាក់ដោយឡែក

ក. គីម សំអាត

នៅក្នុងពន្ធនាគារខេត្តកំពង់ចាម មានបរិយាកាសល្អប្រសើរនិងមានអនាម័យ។ តែពេលនេះជារដូវភ្លៀង ដែលបង្ករអោយមានភាពកខ្វក់ ដោយមានការស្ទះលូសំរាប់បង្ហូរលាមក បណ្តាលអោយហៀរចេញមកក្រៅធ្វើអោយខូចបរិស្ថាន។ ចំពោះបន្ទប់ឃុំអ្នកទោសមានភាពចង្អៀត ព្រោះមានអ្នកទោសកើនឡើងជានិច្ច។ ការចង្អៀតនេះ គឺមកពីពន្ធនាគារគ្មានលទ្ធភាពពង្រីកកន្លែងឃុំឃាំង។ ពន្ធនាគារខេត្តកំពង់ចាម មានអ្នកទោសដែលអនីតិជនចំនួន ២០ នាក់ (ក្មេងអាយុតិចជាង ១៨ ឆ្នាំ)។ បទល្មើសដែលពួកគេបានប្រព្រឹត្តមានការលួច និងការសេពគ្រឿងញៀន។ ការឃុំខ្លួនពួកគេ នៅផ្សេងពីមនុស្សពេញវ័យ។ រៀងរាល់ថ្ងៃ ពួកគេមានពេលជិតមួយម៉ោងដើម្បីសំរាក លេងកីឡា និងសំអាតកាយ។





កុមារក្នុងចំណោមនេះដែលនៅក្នុងពន្ធនាគារពី ២-៤ដង

លោកអនុប្រធានពន្ធនាគារ (រូបខាងឆ្វេង) មានប្រសាសន៍ថា "លោកក៏ចង់អោយមានកន្លែងពិសេសមួយសម្រាប់អនីតិជនដែរ តែពួកលោកគ្មានលទ្ធិភាពទេ។ ក្រៅពីកម្មវិធីខាងលើនេះនៅក្នុងពន្ធនាគារមានការអនុញ្ញាតឱ្យអង្គការផ្សេងៗ បានទៅអប់រំសុខភាព បង្រៀនអក្សរអប់រំអោយចេះកែខ្លួន និងការពិនិត្យព្យាបាលអ្នកទោសណាដែលមានជំងឺ។ មិនតែប៉ុណ្ណោះថែមទាំងមានការអនុញ្ញាត អោយអ្នកទោសបានចេញមកជួបគ្រួសារ ដោយគ្មានរយៈពេលកំណត់ទៀតផង។ ជួលកាលអ្នកខ្លះជួបក្រុមគ្រួសាររហូតមួយម៉ោងឬជិតពីរម៉ោង។ ឯការទទួលទាន គឺម្នាក់ៗ ១០០០ រៀល ក្នុងមួយថ្ងៃ ជាប្រាក់របស់រដ្ឋាភិបាល។ ដូច្នេះហើយការទទួលទានមិនបានគ្រប់គ្រាន់ទេ"។ លោកបានបន្ថែមទៀតថា "ឥឡូវនេះយើងកំពុងមានបញ្ហានិងអគ្គីសនី ជំពាក់គេជាង ៤៤ លានរៀល គឺសម្រាប់បំភ្លឺតែពេលយប់ប៉ុណ្ណោះ។ ចំពោះប្រាក់បៀវត្សបុគ្គលិកវិញ បីបួនខែមិនទាន់បើកម្តង"។



ការលេងកិឡាពេលសំរាក់



បន្ទប់ដែលឃុំអនីតិជន ចំនួន ២០ នាក់



សួនច្បាដាំបន្លែពន្ធនាគារ

**ចំនួនកុមារនៅក្នុងពន្ធនាគារ**

ព្រៃសមានជាង ១០០ នាក់ ខេត្តណ្តាល ១៨ន កំពង់ចាម ២០ន ស្វាយរៀង ៨ន បន្ទាយមានជ័យ ១០ ន កំពង់ឆ្នាំង ៩ ន បាត់ដំបង ៦០ ន កំពង់ស្ពឺ ៦ ន។

## "ពួកគេក៏ដូចយើងដែរ..."

លោក ផាន់ បូរ៉ា ជាគ្រូបង្រៀនក្នុងពន្ធនាគារខេត្តកំពង់ចាម ហើយលោកជាបុគ្គលិកអង្គអារុណរះ។ លោកធ្វើការនេះអស់រយៈ ៦-៧ ខែ កន្លងមកហើយ។ លោកចូលទៅក្នុងពន្ធនាគាររៀងរាល់ថ្ងៃច័ន្ទដល់ថ្ងៃព្រហស្បតិ៍។ នៅទីនោះលោកបានបង្រៀនដល់អ្នកទោសអំពីអនាម័យ អប់រំសុខភាពផ្លូវភេទ អំពីជំងឺអេដស៍ និងអប់រំពួកគេឱ្យចេះកែខ្លួនទៅជាមនុស្សល្អ។ ក្រៅពីកម្មវិធីអប់រំ អង្គការមានចែកជាអំណោយខ្លះៗទៀតផង។



លោកបូរ៉ាបង្រៀនអាន និងសរសេរនៅក្នុងពន្ធនាគារ

លោកបានមានប្រសាសន៍ទៀតថា "កាលលោកចូលធ្វើការក្នុងពន្ធនាគារលើកដំបូង លោកក៏មានការភ័យខ្លាចដែរ តែនៅពេលលោកនៅជាមួយគេយូរទៅ លោកមានអារម្មណ៍ថា ពួកគេក៏ដូចយើងដែរ"។ ក្រោយមកលោកក៏កាន់តែមានទំនាក់ទំនងជាមួយគេជិតស្និទ្ធជាងមុនទៀត។ មានអ្នកទោសខ្លះហ៊ាននិយាយរឿងរ៉ាវរបស់ខ្លួនប្រាប់លោក ហើយអ្នកខ្លះទៀតបានផ្ញើសំបុត្រតាមលោកទៅគ្រួសាររបស់គេទៀតផង។ លោកបានបន្ថែមទៀតថា "នៅពន្ធនាគារមានការលំបាកច្រើនណាស់ ដូចជាការបរិភោគ បន្ទប់ចង្អៀតណែន និងមានការទិញកន្លែងសម្រាក ម្នាក់ ២០០០ ទៅ ៣០០០ រៀល ក្នុងមួយខែពីអ្នកទោសដូចគ្នា"។ រឹតតែមានការលំបាកជាងនេះទៅទៀត គឺសម្រាប់អ្នកដែលមកដល់ថ្មី គេត្រូវរងនូវការធ្វើបាបពីអ្នកទោសមុនៗ ដោយគេនិយាយថា "នេះជាការបង្ក្រាបមួយអោយអ្នកថ្មីចេះគោរពអ្នកចាស់"។ ទោះបីជាលោកមិនអាចជួយគេបានមែន តែលោកអាចជួយលើកទឹកចិត្តគេបានខ្លះដែរ។ លោក បូរ៉ា ក៏ជាគ្រីស្តបរិស័ទម្នាក់ដែលធ្លាប់ជួយកិច្ចការក្នុងព្រះសហគមន៍។ ដ្បិតតែឥឡូវនេះ លោកពុំសូវមានពេលជួយការងារទាំងនោះបន្តទៀតពិតមែន លោកនៅតែជាគ្រីស្តបរិស័ទម្នាក់ដ៏ល្អដដែល។ លោកបាន បំពេញការងារដោយចិត្តស្រឡាញ់ និងដោយអំណរសប្បាយ។ ពេលខ្លះលោកបានរួមជាមួយព្រះសហគមន៍យកអំណោយទៅចែកដល់អ្នកទោសនៅពេលពិធីបុណ្យធំៗ។ នេះជាការលើកទឹកចិត្តមួយ អោយគេចេះកែខ្លួនធ្វើជាពលរដ្ឋល្អទៅថ្ងៃអនាគត ដើម្បីកុំអោយគេគិតថាយើងមានការស្អប់ខ្ពើមពួកគេ។

# "កុមារមានសិទ្ធិស្មើៗគ្នា..."

តាមការរៀបរាប់របស់លោក ស៊ុម ស៊ូយុង ប្រធាន "អង្គការការពារយុត្តិធម៌កុមារ" បានឱ្យដឹងថា "អង្គការមានផ្តល់សេវាកម្មផ្នែកច្បាប់ដល់កុមារជាជនរងគ្រោះ និងកុមារដែលជាជនល្មើស។ ថែមទាំងមានបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ និងអង្គការពាក់ព័ន្ធទៀតផង"។

អង្គការនេះ បានធ្វើការនៅខេត្តបាត់ដំបង កណ្តាល ព្រៃវែង តាកែវ ស្វាយរៀង កំពង់ស្ពឺ និងក្នុងទីក្រុងភ្នំពេញ។

ទោះបីប្រទេសកម្ពុជា មិនមានច្បាប់ស្តីពីសិទ្ធិកុមារត្រឹមត្រូវយ៉ាងណាក៏ដោយ ក៏យើងមានរដ្ឋធម្មនុញ្ញ ដែលធានាការពារសិទ្ធិសេរីភាពកុមារដែរ។ កុមារទាំងអស់មានសិទ្ធិ និងសេរីភាពស្មើៗគ្នា តែការការពារកុមារនៅមានកំរិតនៅឡើយ ទើបកុមារមួយចំនួនទទួលរងនូវការរំលោភបំពាន។ ជាពិសេស កុមារដែលប្រព្រឹត្តបទល្មើស ត្រូវទទួលរងអំពើហិង្សាពីសំណាក់ប៉ូលីស ឬអាជ្ញាធរ និងជនមួយចំនួនទៀត។ ជាទូទៅយើងចាប់អារម្មណ៍តែកុមាររងគ្រោះតែប៉ុណ្ណោះ ចំពោះកុមារជាជនល្មើសវិញយើងមិនបានចាប់អារម្មណ៍ទេ ពួកគេត្រូវឃុំខ្លួនហួសរយៈពេលកំណត់តាមច្បាប់។ តាមគោលការណ៍ កុមារត្រូវមានមេធាវី ដើម្បីការពារពួកគេ។ ដោយភាពខ្វះចន្លោះដូច្នេះហើយ ទើបបណ្តាលឱ្យកុមារមួយចំនួន ទទួលរងនូវ


ស៊ុម ស៊ូយុង ប្រធានអង្គការ (PJJ)

អំពើអយុត្តិធម៌ ត្រូវបានគេចាប់យកទៅឃុំខ្លួនដោយការភ័ណ្ឌច្រឡំ ឬការសង្ស័យ។ ម្យ៉ាងទៀតតាមច្បាប់ កុមារត្រូវមានបន្ទប់ឃុំខ្លួនដោយឡែកពីមនុស្សពេញវ័យ។ ព្រោះកុមារងាយទទួលយកនូវអ្វីៗដែល នៅមានជុំវិញខ្លួនគេដូចជា ការទទួលបទពិសោធន៍អាក្រក់ៗពីមនុស្សពេញវ័យ នេះជាផលវិបាកមួយ នៅពេលគេចេញមកវិញ គេអាចប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរជាងមុនទៀត។ បញ្ហាដែលបណ្តាលឱ្យមានការកើនឡើងនៃចំនួនកុមារក្នុងពន្ធនាគារ គឺបណ្តាលពីភាពក្រីក្រ ការសេពគ្រឿងញៀន ការបញ្ចាំងភាពយន្តអាសអាភាស និងមានក្រុមបងធំ។

ដើម្បីកាត់បន្ថយកំណើននេះ ត្រូវបង្កើនការយកកចិត្តទុកដាក់ទៅលើការអប់រំ គឺរដ្ឋាភិបាលត្រូវមានថវិការមួយពិសេស ដើម្បីជួយដល់កុមារទាំងនោះ ដោយបង្កើតមណ្ឌលមួយសម្រាប់កុមារ ដើម្បីអប់រំគេនៅពេលគេចេញពីពន្ធនាគារ គេអាចធ្វើជាពលរដ្ឋល្អក្នុងសង្គម




និងជាពិសេសជួយពង្រឹងដល់ការការពារកុមារនៅក្នុងពន្ធនាគារ ឱ្យគេរួចផុតពីអំពើហិង្សាថែមទៀតផង។

ក្រៅពីកម្មវិធីខាងលើនេះ អង្គការរបស់លោកមានគំរោងនិងបង្កើតមណ្ឌលយុវនិតិ-សម្បទាមួយ សម្រាប់កុមារណា ដែលមានកំហុសស្រាល ដោយយកគាត់មកអប់រំ និងបង្រៀនវិជ្ជាជីវៈផ្សេងៗ។

ក. គីម សំអាត

### ការខ្សឹបតគ្នា...

មានការត្អូញត្អែរយ៉ាងខ្លាំងពីសំណាក់ក្រុមគ្រួសាររបស់អ្នកទោសនៅគ្រប់ពន្ធនាគារថា "មានការលំបាកណាស់ក្នុងការចូលសួរសុខទុក្ខញាតិសណ្តានព្រោះត្រូវបង់លុយកាក់រាល់ពេល"។ នេះជាបញ្ហាមួយដ៏ធ្ងន់ធ្ងរសម្រាប់គ្រួសារក្រីក្រ។

### ទោះបីប្អូនត្រូវបានបិទសិទ្ធិសេរីភាព...

កាលពីថ្ងៃទី ១ មិថុនា ២០០៤ កន្លងទៅ នៅពន្ធនាគារខេត្តបាត់ដំបងបានប្រារព្ធទិវាសិទ្ធិកុមារអន្តរជាតិ ដែលរៀបចំដោយអង្គការការពារយុត្តិធម៌កុមារ (PJJ)។ ប្អូនៗទណ្ឌិតចំនួន ៦៨ នាក់ ដែលមានអាយុពី ១៣ ដល់ ១៩ ឆ្នាំ ក្នុងនោះមានស្រី ៣ នាក់ដែលបានចូលរួម។ លោកប្រធានអង្គការបានរំលឹកឡើងវិញ នូវបុព្វហេតុដែលធ្វើអោយមានទិវាកុមារអន្តរជាតិនេះឡើង ជាពិសេសលោកបានសង្កត់ធ្ងន់ចំពោះប្អូនៗជាទណ្ឌិតថា "ទោះបីប្អូនៗត្រូវបានបំបិទនូវសិទ្ធិសេរីភាពនៅទីនេះក្តី ក៏ថ្ងៃនេះជាថ្ងៃសំរាប់ប្អូនៗជាពិសេស ដើម្បីលើកទឹកចិត្តប្អូនៗទៅថ្ងៃអនាគតអោយចេះកែខ្លួនរស់នៅជាក្មេងល្អ និងជាពលរដ្ឋល្អក្នុងសង្គម"។

ពន្ធនាគារខេត្តបាត់ដំបងមានពិរុទ្ធជន និងទណ្ឌិតចំនួនប្រហែល ៥០០ នាក់ មានកុមារ និងមនុស្សពេញវ័យ។ កុមារនិងមនុស្សពេញវ័យរស់នៅជាមួយគ្នា។ តាមការសាកសួរអ្នកទោស នៅទីនោះមានការអប់រំចំណេះទូទៅ និងកម្មវិធីផ្សេងៗទៀត។ មតិខ្លះនិយាយថា "ទិវាសិទ្ធិកុមារដែលប្រារព្ធនៅថ្ងៃនេះ មានតែមួយថ្ងៃប៉ុណ្ណោះ ប្អូនៗជាទណ្ឌិតដែលមានសេរីភាព និងត្រូវបានគេយកចិត្តទុកដាក់។ ចុះថ្ងៃផ្សេងតើប្អូនៗមានសេរីភាព និងត្រូវបានគេយកចិត្តទុកដាក់ដូចថ្ងៃនេះដែររឺទេ?"

វណ្ណា



លោកប្រធានពន្ធនាគា (បែមុខ) នឹងអង្គការ PJJ

គំនូរចំណាត់ថ្នាក់លេខ ១ របស់ទណ្ឌិត


ពិធីចែកអំណោយរបស់អង្គការ (PJJ) (KOK) មានស្បែកជើង ភួយ...


ល្បែងសំនួរ ចំលើយអំពីសិទ្ធកុមារ ដែលប្អូនៗពិបាកឆ្លើយ


ការច្រៀងកំសាន្តសប្បាយ


ការរាំកំសាន្តដែលពុំធ្លាប់មានក្នុងមួយឆ្នាំ

## អង្គការមិត្តសំឡាញ់



តាមការរៀបរាប់របស់លោក ពិន សុខុម ដែលជាបុគ្គលិកអង្គការមិត្តសំឡាញ់បានឱ្យដឹងថា "អង្គការនេះធ្វើការជាមួយកុមារអនាថា រស់នៅតាមចញ្ចើមផ្លូវ។ កុមារទាំងនោះមានចំនួនប្រមាណពី ១០.០០០ នាក់ទៅ ២០.០០០ នាក់ ដែលនៅក្នុងទីក្រុងភ្នំពេញ។ ការរងគ្រោះរបស់កុមារទាំងនេះ បណ្ដាលមកពីឪពុកម្ដាយ ស្លាប់ដោយជំងឺអេដស៍ កុមារដែលគេជួញដូរ កុមារប្រើប្រាស់គ្រឿងញៀន និងកុមារដែលរង គ្រោះដោយអំពើផ្សេងៗនៅក្នុងសង្គម។ ក្នុងចំណោមកុមារទាំងនោះមានកុមារ ៥០% ជាអ្នក ដែលប្រើប្រាស់គ្រឿងញៀន"។ តាមការអង្កេតរបស់ UNAIDS អោយដឹងថា "នឹងមានការកើន ឡើងចំនួនកុមារអនាថា នៅក្នុងប៉ុន្មានខែខាងមុខនេះពី ២០% ទៅ ៣០% ដោយបញ្ហាអេដស៍"។ ជាសេចក្ដីព្រួយបារម្ភជាងនេះទៅទៀតនោះគឺ នៅពេលដែលអង្គការបានជួយដល់កុមារទាំងអស់ នោះបញ្ចប់អាណត្តិនៅប្រទេសកម្ពុជា តើកុមារទាំងអស់ដែលនៅក្រោមការគាំទ្ររបស់អង្គការ នឹងទៅជាយ៉ាងណា? នេះជាបញ្ហាចោទមួយយ៉ាងធំសំរាប់សង្គមយើងនៅថ្ងៃអនាគត។

ក. គឹម សំអាត

## អង្គការ CCASVA

អង្គការ CCASVA មានតួនាទីជាអ្នកដើរមើលតាមកន្លែងផ្សេងៗ ដែលមានករណីដូចជាកុមារត្រូវបានគេរំលោភសិទ្ធិ ឬប្រព្រឹត្តអំពើលួចប្លន់ ទាំងអស់នេះកើតឡើងដោយសារតែពួកគេប្រើប្រាស់គ្រឿងញៀនជាដើម។ ដូច្នេះអង្គការនេះធ្វើការទាក់ទង និងផ្ទេរការងារនេះទៅអោយអង្គការលីការដូ អង្គការលីហ្គលអេស ដើម្បីជួយអោយកុមារមានសេវាការពារ និងមានមេធាវីជួយការពារពេលឡើងតុលាការ។ ម្យ៉ាងទៀត អង្គការនេះមានតួនាទី ជាអ្នកចាំទទួលកុមារដែលត្រូវបានរដោះលែងអោយចេញពីពន្ធនាគារ អោយស្នាក់នៅក្នុងមជ្ឈមណ្ឌលស្ដានីតិសម្បទានៅចោមចៅ ដោយមានកន្លែងសំរាប់កុមារស្នាក់នៅ និងបង្រៀនវិជ្ជាជីវៈផ្សេងៗដូចជាៈ ដាំបន្លែ ចិញ្ចឹមសត្វ និងរៀនកាត់ដេរ ។ល។

ក. សារ៉ែន

## ដើម្បីអភិវឌ្ឍន៍សង្គមមួយ ត្រូវអភិវឌ្ឍន៍កុមារជាមុន

នៅក្នុងភូមិត្រីះសន្តិភាព ចោមចៅ មានកម្មវិធីផ្សេងៗសំរាប់កុមារដូចជាៈ ការថែរទាំសុខភាព និងការអប់រំថ្នាក់បឋមសិក្សា។ បងស្រីម្នាក់សុំមិនបញ្ចេញឈ្មោះបានមានប្រសាសន៍ថា "កុមារទាំងនេះជាកុមារដែលរស់នៅភូមិជិតៗកន្លែងបងស្រី និងបានបោះបង់ចោលសាលារៀន ហើយបងស្រីបានទទួលគេមកអប់រំរយៈពេលមួយឆ្នាំ រួចបញ្ជូនគេចូលសាលាវិញ មូលហេតុនៃការអប់រំកុមារនេះ បងស្រីបានបន្តរថា "ដើម្បីអភិវឌ្ឍន៍សង្គមមួយទៅបាន ត្រូវតែអភិវឌ្ឍន៍កុមារមុន..."។ ស្របគ្នានេះដែរ បងស្រីមានសកម្មភាពមួយលើនេះទៀត គឺសួរសុខទុក្ខ និងចែកថ្នាំដល់អ្នកទោសក្នុងពន្ធនាគារ។ បងស្រីបានឱ្យដឹងថា "នៅក្នុងពន្ធនាគារ ពុំមានការថែទាំសុខភាពសំរាប់អ្នកទោសឡើយ ភាគច្រើនមានជំងឺសើស្បែក និងជំងឺរបេង ដោយសារនៅខាងក្នុងពុំ មានអនាម័យល្អម..." កម្មវិធីនេះ បងស្រីបានបញ្ជាក់ថា ពុំមានទាក់ទងជាមួយកុមារទេ មានតែយុវជន និងមនុស្សពេញវ័យ។

វណ្ណា

## លិខិតអ្នកនាំសារ

-អ្នកនាំសារ សូមជំរាបជូនដំណឹងដល់បងប្អូនថា "លេខនេះជាប្រធានបទពិសេសស្ដីពីសិទ្ធិកុមារ យើងខ្ញុំបានព្យាមយាមស្រាវជ្រាវនូវដំណឹងផ្សេងៗដែលទាក់ទងបញ្ហារបស់កុមារ"។

-អ្នកនាំសារ សូមបងប្អូនជួយធ្វើការកែតម្រូវ រឺបងប្អូនមានពត៌មានបន្ថែម សូមផ្ញើមកការិយាល័យយើងខ្ញុំ។

-សូមបងប្អូនសរសេរសំបុត្រផ្ញើមកការិយាល័យព្រឹត្តិបត្រអ្នកនាំសារ។

-យើងខ្ញុំទទួលស្វាគមន៍ជានិច្ចមតិយោបល់ការរិះគន់កែតម្រូវរបស់បងប្អូន។

***សូមអរគុណ !***

ក្រុមនិពន្ធ: គឹម សំអាត
**កុំព្យូទ័រ:** ឡាង ច័ន្ទណាង
ការិល័យផ្សព្វផ្សាយពត៌មានព្រះសហគមន៍
កាតូលិក: #25 St. 242
Boeung Prolet Phnom Penh
Tel-Fax: (855) 23 224 120
csc@catholiccambodia.org
អភិបាលគ្រប់គ្រង:
លោកអភិបាល អេមីល ដេតម្ប
អគ្គនាយក:
លោកបូជាចារ្យ អូមែរ ហ្សីរ៉ាល់ដូ